Sacombank
ធនាគារ សាខមប៉ែង (ខេមបូឌា) ភីអិលស៊ី

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
--------***-------

# លក្ខខណ្ឌ និងគោលការណ៍អនុវត្តកម្មវិធី

## កម្មវិធីដាក់ប្រាក់បញ្ញើដើម្បីអបអរពិធីបុណ្យចូលឆ្នាំប្រពៃណីជាតិខ្មែរ

## និងខួបមួយខួប១០ឆ្នាំនៃការបង្កើតធនាគារ

### I. គោលដៅអតិថិជន

- អតិថិជនឯកត្តជនដាក់ប្រាក់បញ្ញើមានកាលកំណត់ ដាក់ប្រាក់បញ្ញើថ្មី ឬដាក់ប្រាក់បញ្ញើឡើងវិញក្នុងកំឡុងពេលដំណើការកម្មវិធី។

### II. ដែនអនុវត្ត

- គ្រប់ដណ្តប់គ្រប់សាខាទាំងអស់របស់ធនាគារសាខមប៉ែង (ខេមបូឌា)

### III. សុពលភាពនៃកម្មវិធី

- កាលបរិច្ឆេទនៃកម្មវិធីៈ ចាប់ផ្តើមពី**ថ្ងៃច័ន្ទ ទី២៥ ខែកុម្ភៈ ឆ្នាំ២០១៩ រហូតដល់ ថ្ងៃសុក្រ ទី១៤ ខែមិថុនា ឆ្នាំ២០១៩**
- ការចាប់រង្វាន់កាលបរិច្ឆេទប្រកាសអ្នកឈ្នះរង្វាន់ត្រូវបានធ្វើឡើងនៅទីស្នាក់ការកណ្តាលធនាគារសាខមប៉ែង (ខេមបូឌា) ដែលប្រព្រឹត្តិទៅនៅថ្ងៃព្រហស្បតិ៍ ទី២០ ខែមិថុនា ឆ្នាំ២០១៩។

### IV. ខ្លឹមសារនៃកម្មវិធី

ក្រោយពេលអតិថិជនដាក់ប្រាក់បញ្ញើ និងចូលរួមកម្មវិធីអតិថិជននឹងមានឱកាសទទួលបានរង្វាន់ចំនួន០២ដងៈទទួលបានរង្វាន់ភ្លាមៗនៅពេលដាក់ប្រាក់បញ្ញើ និងទទួលបានលេខកូដផ្សងសំណាងដើម្បីចូលរួមកម្មវិធីចាប់រង្វាន់នៅចុងបញ្ចប់នៃកម្មវិធី។

**១. លក្ខខណ្ឌចូលរួមកម្មវិធីៈ**

- ✓ ប្រភេទប្រាក់បញ្ញើៈ ប្រាក់រៀល ឬ ដុល្លារអាមេរិច។
- ✓ សមតុល្យបើកអប្បបរមាចាប់ពី ១.០០០ ដុល្លារអាមេរិក ឬ ៤០០០០០០ លានរៀលឡើងទៅ។
- ✓ រយៈពេល អនុវត្តរាល់ប្រាក់បញ្ញើដែលមានរយៈពេលចាប់ពី ១ ខែឡើងទៅ។
- ✓ មិនអនុវត្តចំពោះផលិតផលប្រាក់បញ្ញើកាលកំណត់បត់បែន (Flexible Fixed Deposit) និងគណនីប្រាក់បញ្ញើសម្រាប់អនាគត (Future Deposit)។
- ✓ បុគ្គលិកធនាគារសាខមប៉ែង (ខេមបូឌា)មិនមានសិទ្ធចូលរួមកម្មវិធី។

**២. អត្រាការប្រាក់ប្រាក់បញ្ញើរចូលរួមកម្មវិធី**

- អនុវត្តទៅតាមតារាងអត្រាការប្រាក់ដែលចេញក្នុងរយៈពេលដាក់ប្រាក់បញ្ញើរ

**៣. របៀបនៃការគណនាចំនួនលេខកូដសំណាង**

- ចំនួនលេខកូដសំណាងត្រូវបានគិតទៅតាមរូបមន្តដូចខាងក្រោមៈ (គិតតែចំនួនលេខគត់-មិនគិតលេខបង្គត់)
  - ✓ ចំពោះប្រាក់ដុល្លារ

ចំនួនលេខកូដសំណាង=(ចំនួនប្រាក់បញ្ញើរ X រយៈពេល)/៦.០០០

- ✓ ចំពោះប្រាក់រៀល

ចំនួនលេខកូដសំណាង=(ចំនួនប្រាក់បញ្ញើ X រយៈពេល)/២៤.០០០.០០០

ឧទាហរណ៍ទី ១ ៖ អតិថិជនដាក់ប្រាក់បញ្ញើ ៥.០០០ ដុល្លារ រយៈពេល ៦ ខែ ➔ លេខកូដសំណាងដែលអតិថិជនទទួលបានគឺ: ០៥ លេខកូដ

ឧទាហរណ៍ទី ២ ៖ អតិថិជនដាក់ប្រាក់បញ្ញើ ១៥.០០០ ដុល្លារ រយៈពេល ៦ ខែ ➔ លទ្ធផលគឺ ១៥.៥➔ លេខកូដសំណាងដែលអតិថិជនទទួលបានគឺ: ១៥ លេខកូដ

ឧទាហរណ៍ទី ៣ ៖ អតិថិជនដាក់ប្រាក់បញ្ញើ ២០លាន រៀល រយៈពេល ៦ ខែ ➔ លេខកូដសំណាងដែលអតិថិជនទទួលបានគឺ: ០៥ លេខកូដ

ឧទាហរណ៍ទី ៤ ៖ អតិថិជនដាក់ប្រាក់បញ្ញើ ៣៥ លាន រៀល រយៈពេល ៦ ខែ ➔ លទ្ធផលគឺ ៨.៧៥➔ លេខកូដសំណាងដែលអតិថិជនទទួលបានគឺ: ០៨ លេខកូដ

- រាល់លេខកូដសំណាងគឺមានអក្សរ ១តួរ និងលេខចំនួន ៥ **ឧទាហរណ៍: A12345**។ លេខកូដសំណាងគឺត្រូវបានបោះពុម្ពចេញពីកម្មវិធីផ្តល់ និងគ្រប់គ្រងលេខកូដសំណាង

**៤. រង្វាន់សម្រាប់ការចូលរួមកម្មវិធី**

**ក. រង្វាន់ជាវត្ថុអនុស្សាវរីយ៍ផ្តល់ជូនភ្លាមៗ**

| រង្វាន់អនុស្សាវរីផ្តល់ជូនដំណាក់កាលទី១ (ថ្ងៃច័ន្ទ ទី២៥ ខែកុម្ភៈ ឆ្នាំ ២០១៩រហូតដល់ថ្ងៃសុក្រ ទី១២ ខែមេសា ឆ្នាំ២០១៩) | | |
|---|---|---|
| **ល.រ** | **ប្រភេទរង្វាន់** | **ចំនួន** |
| ១ | ឆ័ត្រ សម្រាប់ការពារភ្លៀង ការពារថ្ងៃ ក្តៅមានស្លាកសញ្ញារបស់ធនាគារសាខមប៉ែង (ខេមបូឌា) អតិថិជនអាចប្រើប្រាស់ឆ័ត្រសម្រាប់ទៅវត្តក្នុងឱកាសបុណ្យទាន ចូលឆ្នាំ។ | ៥០០ |
| **រង្វាន់អនុស្សាវរីផ្តល់ជូនដំណាក់កាលទី២ (ថ្ងៃព្រហស្បតិ៍ ទី១៨ ខែមេសា ឆ្នាំ២០១៩រហូតដល់ថ្ងៃសុក្រ ទី១៤ ខែមិថុនា ឆ្នាំ២០១៩)** | | |
| ១ | ប៊ិចអនុស្សាវរីយ៍ប្រភេទ ២ (រួមទាំងប្រអប់) មានស្លាកសញ្ញារបស់ធនាគារសាខមប៉ែង (ខេមបូឌា) សម្រាប់អតិថិជនដែលមានលេខកូដសំណាងចាប់ពី ១០ លេខឡើងទៅ។ | ៤០០ |
| ២ | ប៊ិចអនុស្សាវរីយ៍ប្រភេទ ១ មានស្លាកសញ្ញារបស់ធនាគារសាខមប៉ែង (ខេមបូឌា) សម្រាប់អតិថិជនដែលមានលេខកូដសំណាងចាប់ពី ១០០ លេខឡើងទៅ។ | ១០០ |

**- លក្ខខណ្ឌទទួលរង្វាន់**

- អតិថិជនចូលរួមកម្មវិធី និងមានលេខកូដផ្សងសំណាង**យ៉ាងតិច ១០ លេខកូដ** អតិថិជននឹងទទួលបានរង្វាន់ចំនួនមួយ (ឆ័ត្រ នៅតំណាក់កាលទី ១ ឬ ប៊ិចអនុស្សាវរីយ៍នៅតំណាក់កាលទី ២)
- ប្រសិនបើមិនទាន់គ្រប់ ១០ លេខកូដដើម្បីទទួលរង្វាន់ អតិថិជនអាចបូកបន្ថែមលេខកូដដើម្បីប្តូររង្វាន់នៅពេលគ្រប់លក្ខំណ
- រាល់ដំណាក់កាល អតិថិជនម្នាក់អាចទទួលបានរង្វាន់តែមួយរង្វាន់
- អតិថិជន១០០នាក់ដំបូងដាក់ប្រាក់បញ្ញើក្នុង ២ ដំណាក់កាលដែលមានលេខកូដផ្សងចាប់ពី ១០០ លេខកូដឡើងទៅ (១០០ពាន់ ដុល្លា រយៈពេល ៦ ខែ) នឹងទទួលបានប៊ិចអនុស្សាវរីយ៍ប្រភេទ ១។
- អតិថិជនដែលទទួលបានរង្វាន់ក្នុងដំណាក់កាលទី ១ ក៏អាចទទួលបានរង្វាន់នៅដំណាក់កាលទី ២ ប្រសិនបើអតិថិជននៅបន្តចូលរួមកម្មវិធីហើយទទួលបានលេខកូដសំណាងចាប់ពី ១០ លេខកូដឡើងទៅ។

- ពិន្ទុដែលសន្សំមានសុពលភាពទៅតាមដំណាក់កាលនីមួយៗ
- អតិថិជនដាក់ប្រាក់បញ្ញើនៅតាមសាខាណានឹងទទួលរង្វាន់នៅសាខានោះ

**៤. ប្រភេទរង្វាន់ចាប់ឆ្នោតផ្សងសំណាង**

| ល.រ | រង្វាន់ | ចំនួនរង្វាន់ |
|---|---|---|
| ១ | រង្វាន់ពិសេស មាសសុទ្ធ ២ តម្លឹង | ១ |
| ២ | រង្វាន់ទី ១ មាសសុទ្ធ ១ តម្លឹង | ១ |
| ៣ | រង្វាន់ទី ២ ទូរស័ព្ទ iPhone Xs | ២ |
| ៤ | រង្វាន់ទី ៣ ទូរទស្សន៍ Samsung 49 អ៊ីង | ៣ |

- <u>សំគាល់:</u> រង្វាន់ទទួលបានពីកម្មវិធីមិនអាចប្តូរយកប្រាក់បានឡើយ។

**៥. លក្ខខណ្ឌបិទមុនកំណត់**

- ក្នុងរយៈពេលនៃដំណើរការនៃកម្មវិធី និងមុនពេលចាប់រង្វាន់អតិថិជនអាចបិទមុនកំណត់។ ធនាគារសាខមប៉ែង (ខេមបូឌា) និងលុបចោលរាល់លេខកូដផ្សងសំណាងដែលរៀងគ្នាជាមួយសៀវភៅប្រាក់បញ្ញើដែលអតិថិជនបានចូលរួមជាមួយកម្មវិធី។

- ក្រោយថ្ងៃ សុក្រ ទី ១៤ ខែ មិថុនា ឆ្នាំ ២០១៩ អតិថិជនមិនអាចបិទមុនកំណត់បានឡើយ ពេលអតិថិជនមានតម្រូវការប្រើប្រាស់ទុន អតិថិជនអាចធ្វើការដាក់បញ្ចាំវិញនៅសៀវភៅប្រាក់បញ្ញើ។

**៦. បទបញ្ញត្តិផ្សេងៗរបស់កម្មវិធី:**

- ធនាគារសាខមប៉ែង (ខេមបូឌា) និងធ្វើសេចក្តីជូនដំណឹងពេញលេញពីលក្ខខ័ណ្ឌ និងគោលការណ៍អនុវត្តកម្មវិធីលើគេហទំព័រ https://www.sacombank.com.kh/en/product/deposit-promotion/

- ធនាគារសាខមប៉ែង (ខេមបូឌា) និងធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះអតិថិជនដែលទទួលបានរង្វាន់នៅលើគេហទំព័រ: https://www.sacombank.com.kh/en/product/deposit-promotion/

- ពេលមកទទួលរង្វាន់ អតិថិជនត្រូវភ្ជាប់ជាមួយឯកសារដូចជា: អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន (ច្បាប់ដើម) សៀវភៅប្រាក់បញ្ញើ/ចុងសន្លឹកដែលមានបោះពុម្ពលេខកូដសំណាងរបស់កម្មវិធី(ប្រសិនមាន)។

- អតិថិជនត្រូវទទួលខុសត្រូវលើពន្ធផ្សេងៗដែលពាក់ព័ន្ធជាមួយរង្វាន់ ថ្លៃដឹកជញ្ជូនរង្វាន់ទៅគេហដ្ឋាន។

- ធនាគារសាខមប៉ែង (ខេមបូឌា) មានសិទ្ធផ្លាស់ប្តូរ លុបឬបំពេញបន្ថែមនូវប្រការ ឬលក្ខខ័ណ្ឌខ្លឹមសារនៃកម្មវិធីនេះដោយមិនបាច់ធ្វើការជូនដំណឹងមុនដល់អតិថិជន។

- ធនាគារសាខមប៉ែង (ខេមបូឌា) មិនទទួលខុសត្រូវនៅរាល់ករណីប្រធានស័កដែលកើតមានឡើងក្នុងរយៈពេលដំណើរការកម្មវិធី ឬធនាគារសាខមប៉ែង (ខេមបូឌា) មិនអាចធ្វើការទំនាក់ទំនងជូនដំណឹងអតិថិជនមកទទួលរង្វាន់។

- ធនាគារសាខមប៉ែង (ខេមបូឌា) មានសិទ្ធប្រើប្រាស់រូបភាព ឈ្មោះ និងអាសយដ្ឋានរបស់អតិថិជនដែលត្រូវរង្វាន់ក្នុងគោលបំណងផ្សព្វផ្សាយរូបភាព កម្មវិធី និងផលិតផលសេវាកម្មរបស់ធនាគារសាខមប៉ែង (ខេមបូឌា)។

- ក្រោយរយៈពេល ៦០ ថ្ងៃចាប់ពីថ្ងៃនៃកម្មវិធីត្រូវបានបញ្ចប់ ធនាគារសាខមប៉ែង (ខេមបូឌា) និងមិនទទួលរាល់បណ្តឹងណាមួយរបស់អតិថិជន រួមទាំងករណីដែលធនាគារសាខមប៉ែង (ខេមបូឌា) មិនអាចទំនាក់ទំនងអតិថិជនដើម្បីទទួលរង្វាន់។

- រាល់ចម្ងល់ផ្សេងៗដែលពាក់ព័ន្ធជាមួយកម្មវិធី អតិថិជនអាចធ្វើការទំនាក់ទំនងទៅតាមអាសយដ្ឋានដូចខាងក្រោម:

Call Center: 023 223 423/0978 223 423

អាសយដ្ឋាន: អគារ ៦០ មហាវិថីព្រះនរោត្តម សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

**ធនាគារសាខមប៉ែង (ខេមបូឌា)**